ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២៥៤១ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលក្នុងការប្រកាសបង់ពន្ធប៉ាតង់របស់សហគ្រាស ប្រកាសបង់ពន្ធតាមរបបស្វ័យប្រកាសសម្រាប់ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៥

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីម្ចាស់សហគ្រាស ដែលប្រកាសបង់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ជ្រាបថា ឆ្នាំ២០១៥នេះសហគ្រាសដែលបានចុះបញ្ជីពន្ធដារមុនខែវិច្ឆិកា ឆ្នាំ២០១៤ ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដែលតម្រូវឱ្យភ្ជាប់ឯកសារពាក់ព័ន្ធផ្សេងៗមួយចំនួន ហើយត្រូវប្រកាសបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំ២០១៥ក្នុងពេលតែមួយ។ ប្រការនេះបណ្តាលឱ្យសហគ្រាសមួយចំនួនមិនទាន់បានប្រកាសបង់ពន្ធប៉ាតង់បានទាន់ពេលវេលានៅឡើយ។

ដើម្បីទុកលទ្ធភាពជូនសហគ្រាសដែលមិនទាន់បានប្រកាសបង់ពន្ធ ឬនៅខ្វះឯកសារផ្សេងៗ មានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំនូវឯកសារពាក់ព័ន្ធសម្រាប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស អគ្គនាយកដ្ឋានពន្ធដារសូមពន្យារពេលដល់ការប្រកាសបង់ពន្ធប៉ាតង់ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៥។

ក្នុងករណីដែលសហគ្រាសមានការយឺតយ៉ាវក្នុងការមកប្រកាសបង់ពន្ធប៉ាតង់ឆ្នាំ២០១៥ តាមការពន្យារពេលខាងលើ សហគ្រាសនឹងត្រូវទទួលរងនូវទោសទណ្ឌដោយត្រូវបង់ប្រាក់ពន្ធ និងបង់ប្រាក់ផាកពិន័យស្របតាមច្បាប់ស្តីពីសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលពន្យារនេះ លោក-លោកស្រីម្ចាស់សហគ្រាសដែលមិនទាន់បានប្រកាសបង់ពន្ធប៉ាតង់ នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលាតាមការកំណត់នេះជាក់ជាពុំខាន។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

**KINGDOM OF CAMBODIA**
**Nation Religion King**

Ministry of Economy and Finance

General Department of Taxation
No. 2546 អពដ

Phnom Penh, 27 April 2015

**Instruction**
**On**
**Patent Tax Declaration Postponement of Real Regime Enterprise for the Year 2015 To 31 May 2015**

The General Department of Taxation would honorably like to inform owners of enterprises declaring real regime tax that for this 2015 any enterprises registered before November 2014 shall be subject to updating enterprise information which is required to attach with some documents and that the Patent Tax 2015 shall be declare at the same time. This has made patent tax declaration of some enterprises delayed.

Providing enterprises, which have not yet done the tax declaration or had sufficient documents, with sufficient times to prepare relevant documents for enterprise information updating, the General Department of Taxation would like to postpone the Patent Tax 2015 declaration to 31 May 2015.

In case of being late with the Patent Tax 2015 declaration though the postponement, the breaching enterprise shall be punished by paying the tax and penalty amounts in accordance with the Law on Taxation.

The General Department of Taxation strongly hopes that, during the postponement, owners of enterprises, who have not yet paid the Patent Tax, would pay the tax duty timely.

Delegate of the Royal Government

In charge of the General Department of Taxation

**KONG Vibol**

*Un-official translation by SM Global Accounting & Consulting Co., Ltd.*